ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
******

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ
******

## ជំនួបរវាងឯកឧត្តម ប្រាក់ សុខុន ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និង លោកជំទាវ Donica Pottie ឯកអគ្គរដ្ឋទូតកាណាដា ប្រចាំកម្ពុជា

******

នៅព្រឹកថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១៧ វេលាម៉ោង០៩:៣០ នៅទីស្តីការក្រសួង **ឯកឧត្តម ប្រាក់ សុខុន** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានអនុញ្ញាតឲ្យ **លោកជំទាវ** Donica Pottie ឯកអគ្គរដ្ឋទូតកាណាដា ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ដែលមាននិវេសនដ្ឋាន នៅទីក្រុងបាងកក ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារ។

នៅក្នុងជំនួបនោះ **ឯកឧត្តមទេសរដ្ឋមន្ត្រី** បានរំលឹកឡើងវិញអំពីជំនួបពិភាក្សាការងាររវាង **ឯកឧត្តម**ផ្ទាល់ ជាមួយអតីតរដ្ឋមន្ត្រីការបរទេសកាណាដា **ឯកឧត្តម** Stéphane Dion ក្នុងឱកាសអញ្ជើញចូលរួមកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ាន នៅទីក្រុងវៀងច័ន្ទ ប្រទេសឡាវ នាខែកក្កដា ឆ្នាំ២០១៦ និងក្នុងដំណើរទស្សនកិច្ចផ្លូវការរបស់**ឯកឧត្តម** Stéphane Dion មកកាន់កម្ពុជា នៅដើមខែកញ្ញា ឆ្នាំ២០១៦។ **ឯកឧត្តមទេសរដ្ឋមន្ត្រី** បានរំឭកថា ភាគីទាំងពីរបានពិភាក្សាផ្លាស់ប្តូរយោបល់គ្នាលើបញ្ហាជាច្រើន ជុំវិញការពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរ និងបានផ្លាស់ប្តូរទស្សនៈគ្នាពាក់ព័ន្ធនឹងសភាពការណ៍តំបន់ និងអន្តរជាតិ ដែលមានផលប្រយោជន៍ដល់ភាគីទាំងពីរ។ **ឯកឧត្តមទេសរដ្ឋមន្ត្រី** បានសម្តែងនូវការពេញចិត្តចំពោះការរីកចំរើនក្នុងទំនាក់ទំនងសហប្រតិបត្តិការទ្វេភាគី ពិសេសការបើកការិយាល័យការទូតកាណាដា នៅទីក្រុងភ្នំពេញ នាខែធ្នូ ឆ្នាំ២០១៥ ហើយដែលត្រូវបានសម្ពោធជាផ្លូវការក្នុងឱកាសទស្សនកិច្ចឯកឧត្តម Stéphane Dion។

**ឯកឧត្តមទេសរដ្ឋមន្ត្រី** បានថ្លែងអំណរគុណក្នុងនាមរាជរដ្ឋាភិបាល និងប្រជាជនកម្ពុជា ចំពោះជំនួយឧបត្ថម្ភរបស់កាណាដា ក្នុងរយៈកាលកន្លងមក ពិសេសនៅលើវិស័យកសិកម្ម សន្តិសុខ-ម្ហូបអាហារ សកម្មភាពដោះមីន ការប្រឆាំងនឹងការជួញដូរមនុស្ស ។ល។ ថ្វីត្បិតកម្មវិធីជំនួយអភិ-វឌ្ឍន៍ទ្វេភាគីនេះបានបញ្ចប់ក្នុងឆ្នាំ២០១២។

**ឯកឧត្តមទេសរដ្ឋមន្ត្រី** បានលើកឡើងពីការត្រៀមខ្លួនរបស់**ឯកឧត្តម**ផ្ទាល់ ក៏ដូចជារបស់ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ក្នុងការផ្តល់នូវការគាំទ្រដល់**លោកជំទាវ** និងការិយាល័យការទូតកាណាដានៅភ្នំពេញ ដើម្បីអនុវត្តភារកិច្ចការទូតប្រកបដោយជោគជ័យ។

**លោកជំទាវ** Donica Pottie បានជំរាបជូន **ឯកឧត្តមទេសរដ្ឋមន្ត្រី** អំពីមនោសញ្ចេតនារីករាយពេញចិត្តរបស់លោកជំទាវផ្ទាល់ ដែលត្រូវបានតែងតាំងជាឯកអគ្គរដ្ឋទូតកាណាដា ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ចំនួន២លើក ដែលលើកទី១ នាឆ្នាំ២០០៤ - ២០០៧។

**លោកជំទាវ**ឯកអគ្គរដ្ឋទូត បានវាយតម្លៃខ្ពស់ចំពោះការរីកចំរើនក្នុងកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរ និងការបើកការិយាល័យការទូតកាណាដានៅភ្នំពេញ ហើយបានជំរាបជូន **ឯកឧត្តមទេសរដ្ឋមន្ត្រី** អំពីការយកចិត្តទុកដាក់របស់កាណាដា ក្នុងកិច្ចសហប្រតិបត្តិការជាមួយកម្ពុជា លើផ្នែកសកម្មភាពដោះមីន សន្តិសុខ ការប្រឆាំងនឹងភេរវកម្ម និងការជួញដូរមនុស្ស។

**លោកជំទាវ**ឯកអគ្គរដ្ឋទូត បានវាយតម្លៃខ្ពស់ចំពោះការកើនឡើង ក្នុងការផ្លាស់ប្តូរពាណិជ្ជកម្មរវាងប្រទេសទាំងពីរ ហើយបានសម្តែងនូវការចាប់អារម្មណ៍យ៉ាងខ្លាំងចំពោះការរីកចំរើនផ្នែកសេដ្ឋកិច្ចកម្ពុជា ពិសេសគឺកម្ពុជាត្រូវបានចាត់បញ្ចូលទៅក្នុងក្រុមប្រទេសដែលមានចំណូលមធ្យមកំរិតទាប។ លោកជំទាវបានគូសបញ្ជាក់ថា ការរីកចំរើនផ្នែកសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជានេះ ត្រូវបានចាប់អារម្មណ៍និងទទួលស្គាល់ ហើយកំពុងតែមានភាពទាក់ទាញសំរាប់វិនិយោគិនកាណាដា។

**ឯកឧត្តមទេសរដ្ឋមន្ត្រី** ក៏បានជម្រាបជូន**លោកជំទាវ** អំពីការខិតខំរបស់រាជរដ្ឋាភិបាលកម្ពុជា តាមរយៈអាជ្ញាធរមីន និងមជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា ក្នុងការបោសសម្អាតមីននៅក្នុងប្រទេស ហើយ**ឯកឧត្តម**បានគូសបញ្ជាក់ថា ថ្វីត្បិតទទួលបានសមិទ្ធិផលធំធេង ប៉ុន្តែទន្ទឹមនឹងនោះក៏កំពុងប្រឈមបញ្ហាកង្វះខាតផ្នែកហិរញ្ញវត្ថុ។ **ឯកឧត្តម** ស្នើសុំឲ្យកាណាដាពិនិត្យលទ្ធភាពផ្តល់ការជួយគាំទ្រទាំងផ្នែកបច្ចេកទេស និងហរិញ្ញវត្ថុដល់សកម្មភាពបោសសំអាតមីននៅកម្ពុជា។

**ឯកឧត្តមទេសរដ្ឋមន្ត្រី** និង**លោកជំទាវ** ក៏បានផ្លាស់ប្តូរយោបល់គ្នាផងដែរ អំពីសភាពការណ៍តំបន់និងអន្តរជាតិមួយចំនួន។ នៅក្នុងក្របខ័ណ្ឌអាស៊ាន **លោកជំទាវឯកអគ្គរដ្ឋទូត** បានស្នើសុំឲ្យកម្ពុជាផ្តល់ការគាំទ្រចំពោះវត្តមានចូលរួមរបស់កាណាដា នៅក្នុងកិច្ចប្រជុំកំពូលអាស៊ីបូព៌ា ដែលនឹងប្រព្រឹត្តិទៅនាពេលខាងមុខ នៅប្រទេសហ្វីលីពីន ដោយប្រទេសកាណាដា ត្រូវបានអញ្ជើញឲ្យចូលរួមក្នុងកិច្ចប្រជុំកំពូលអាស៊ីបូព៌ានេះ ក្នុងឋានៈជាភ្ញៀវរបស់ប្រទេសម្ចាស់ផ្ទះ។ **លោកជំទាវឯកអគ្គរដ្ឋទូត** ក៏បានលើកអំពីសំណើរបស់រដ្ឋាភិបាលកាណាដា សុំការគាំទ្រពីកម្ពុជាចំពោះបេក្ខភាពរបស់កាណាដាជាសមាជិកមិនអចិន្ត្រៃយ៍នៃក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ សម្រាប់អាណត្តិឆ្នាំ ២០២០ - ២០២១។

**ឯកឧត្តមទេសរដ្ឋមន្ត្រី** បានរំលឹកឡើងវិញពីសំណើរបស់កម្ពុជាសុំការគាំទ្ររបស់កាណាដាចំពោះបេក្ខភាពកម្ពុជាក្នុងអង្គការ ECOSOC សំរាប់អាណត្តិឆ្នាំ២០១៩ និងបានផ្តល់យោបល់ឲ្យមានការផ្លាស់ប្តូរការគាំទ្រគ្នាទៅវិញទៅមក។

ជំនួបនេះ បានបញ្ចប់ក្នុងបរិយាកាសរីករាយ និងស្និទ្ធស្នាល។

ភ្នំពេញ ថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ២០១៧